# ជំពូក ៧

# យុទ្ធសាស្ត្ររបស់ប្រជាពលរដ្ឋសាមញ្ញ

គេដឹងច្បាស់ថា ប្រជាពលរដ្ឋពិតជាមានប្រតិកម្មចំពោះការប្រព្រឹត្តអំពើពុករលួយ ដូចបានបង្ហាញនៅក្នុងផ្នែក ២ ។ ក៏ប៉ុន្តែ គេអាចសួរថា តើមានយុទ្ធសាស្ត្រប្រកបដោយមនសិការនៅពីក្រោយប្រតិកម្មនេះដែរឬទេ និងថា តើប្រតិកម្មទាំងនេះ អាចត្រូវបានចាត់ទុកថា ជាការប្រឆាំងដែរឬទេ ឬ គ្រាន់តែជាយន្តការ (វិធីសាស្ត្រ) ដោះស្រាយប៉ុណ្ណោះ ។

ជំពូក ៧ ផ្អែកទាំងស្រុងទៅលើរឿងរ៉ាវរបស់គ្រួសារ **វ៉ាន** និង រឿងរ៉ាវលោក **សុខា** ដែលរៀបរាប់អំពីការប្រឈមមុខជាមួយមន្ត្រីរាជការនៅតាមការិយាធិបតេយ្យ និង ស្ថាប័នក្នុងមូលដ្ឋាន ដែលគ្មានខ្សែរយៈដើម្បីធានាសន្តិសុខ ។ ជំពូកនេះមានលទ្ធផលសំខាន់ៗចំនួន ៤ ។ ទីមួយ កង្វះព័ត៌មានគួបផ្សំជាមួយនឹងការគំរាមកំហែង ធ្វើឱ្យការកេងប្រវ័ញ្ចកាន់តែមានភាពងាយស្រួល ។ ទីពីរ គ្រួសាររបស់ វ៉ាន និង លោក សុខា មានអារម្មណ៍ថា ខ្លួនមានលទ្ធភាពតិចតួចក្នុងការប្រឆាំងតបតទៅនឹងការប្រព្រឹត្តអំពើពុករលួយ ។ ក៏ប៉ុន្តែ សកម្មភាពទាំងនេះគ្រាន់តែជាសញ្ញាដ៏តូចមួយនៃការប្រឆាំងដែលមានលក្ខណៈពិសេសផ្អែកតាមសីលធម៌ប៉ុណ្ណោះ ។ ទីបី គ្រឿងលើកទឹកចិត្តក្នុងការកែលំអជីវភាពរស់នៅ និង កំណើនជីវភាព ត្រូវបានរាំងដោយការបង់លុយសូកប៉ាន់ និង កង្វះហេដ្ឋារចនាសម្ព័ន្ធដែលបំពេញមុខងារយ៉ាងល្អដូចជា ទីផ្សារ និង ការអនុវត្ត ប្រព័ន្ធច្បាប់ជាដើម ។ ទីបួន ការប្រឆាំងដ៏សកម្មត្រូវបានជាប់គាំងដោយសាររចនាសម្ព័ន្ធអំណាចដែលបង្កើតឡើងដោយផ្អែកតាមវប្បធម៌ ។

## ៧.១ គ្រួសារលោក វ៉ាន មានអារម្មណ៍ថា មានសេរីភាពតិចតួចក្នុងការប្រឆាំងនឹងអំពើពុករលួយ

បញ្ហាដ៏ធំសំរាប់ប្រជាពលរដ្ឋ ជាពិសេសសំរាប់ប្រជាជនក្រីក្រ គឺនៅពេលដែលមន្ត្រីប៉ូលីសស្លៀកឯកសណ្ឋានចុះមកគេហដ្ឋានជាលក្ខណៈឯកជនដើម្បីសុំប្រាក់ ។ ជាញឹកញាប់ អ្នកដែលនៅផ្ទះគឺស្ត្រី និង កុមារ ហើយប៉ូលីសត្រូវបានគេយល់ឃើញថា ប្រើការបំភិតបំភ័យ និង គំរាមកំហែង ជាពិសេសដោយសារតែជាធម្មតា ប៉ូលីសធ្វើប្រតិបត្តិការជាក្រុមដែលមានគ្នា ២ ឬ ៣នាក់ ។ ស្ថានភាពដូចនេះត្រូវបានបង្ហាញនៅក្នុងប្រអប់ ៦ ខាងក្រោមនេះ ។

**ប្រអប់ទី ៦ : បទសម្ភាសន៍ជាមួយលោក និង លោកស្រី វ៉ាន**

លោក វ៉ាន គឺជាអ្នកនេសាទម្នាក់ដែលរស់នៅក្នុងតំបន់ជនបទមួយក្បែរសមុទ្រ ។ លោក វ៉ាន មានកូន ១០នាក់ ហើយកូន ៩នាក់ រស់នៅជាមួយលោក និង ភរិយារបស់លោកនៅឡើយ នៅក្នុងខ្ទមឫស្សីតូចពីរដែលមានដំបូលប្រក់ស្លឹក ។ ដីដែលគ្រួសារលោករស់នៅមិនមែនជាដីកម្មសិទ្ធិរបស់លោកទេ ហើយគ្មានទឹកស្អាត ឬ អគ្គិសនីប្រើប្រាស់ទេ ។ គ្រួសារនេះមានទូកនេសាទតូចមួយ ហើយលោក វ៉ាន ចេញទៅនេសាទត្រីរៀងរាល់ព្រឹកជាមួយកូន ៣នាក់ របស់លោក និង អ្នកជិតខាងម្នាក់ ប្រសិនបើអាកាសធាតុមិនអាក្រក់ ។ លោក វ៉ាន បានស្គាល់អ្នកជិតខាងអស់ច្រើនឆ្នាំមកហើយ បច្ចុប្បន្ននេះ អ្នកជិតខាងរូបនេះស្ទើរតែក្លាយជាសមាជិកគ្រួសារលោក វ៉ាន ទៅហើយ ។ លោក វ៉ាន កូន និង អ្នកជិតខាងនេសាទត្រីដោយប្រើសំណាញ់ ហើយនៅពេលដែលលោក វ៉ាន កូន និង អ្នកជិតខាងនេសាទបានត្រីគ្រប់គ្រាន់ ភរិយារបស់លោក វ៉ាន លក់ត្រីដែលលើសពីតំរូវការគ្រួសារទៅផ្សារនៅពេលថ្ងៃត្រង់ ហើយទិញអង្ករយកមកផ្ទះវិញ ។

គ្រួសារលោក វ៉ាន កំពុងអង្គុយនៅខាងមុខខ្ទមឫស្សីមួយក្នុងចំណោមខ្ទមទាំងពីរ លើគ្រែឫស្សីដើម្បីពិភាក្សាអំពីស្ថានភាពគ្រួសាររបស់ខ្លួន ។ ពេលនោះ ជាពេលរសៀល ហើយកូនៗទាំងអស់សំរាកនៅផ្ទះដើម្បីជ្រកម្លប់ ហើយលោកស្រី វ៉ាន កំពុងរកថៃអោយកូនម្នាក់នៅពេលដែលនាង (កូន) ចូលរួមក្នុងការសន្ទនានេះ ។

នៅពេលដែលគេសួរលោក និង លោកស្រី វ៉ាន ថា តើលោក និង លោកស្រី វ៉ាន ធ្លាប់ជួបប្រទះអំពើពុករលួយ ឬ អត់ លោកស្រី វ៉ាន រៀបរាប់ថា ជួនកាល ប៉ូលីសបានចុះមកផ្ទះលោកស្រីដើម្បីសុំប្រាក់ ខណៈពេលលោកស្រីនៅផ្ទះតែម្នាក់ឯង ។ ជួនកាល លោកស្រីបង់ប្រាក់ ៥,០០០ ឬ ៦,០០០រៀល បើទោះបីជាប៉ូលីសទាំងនោះទាមទារ ២០,០០០រៀលក៏ដោយ ប៉ុន្តែជួនកាល លោកស្រីនិយាយប្រាប់ប៉ូលីសថា លោកស្រីគ្មានលុយជាប់ខ្លួនទេ និង ថា គ្រួសារលោកស្រីរកមុខរបរចិញ្ចឹមជីវិតនៅសមុទ្រហើយក្រណាស់ ។ លោកស្រីមិនដឹងថា ប៉ូលីសយកលុយនេះសំរាប់គោលបំណងអ្វី ឬ មិនដឹងពីមូលហេតុដែលលោកស្រីគួរបង់ប្រាក់ទេ ។

*ខ្ញុំមិនដឹងថា ប៉ូលីសយកលុយនេះសំរាប់គោលបំណងអ្វីនោះទេ ។ ប៉ូលីសទាំងនោះគ្រាន់តែនិយាយថា ខ្លួនយកប្រាក់ទាំងនេះដើម្បីទិញអាហារ និង បារី ។ ខ្ញុំមិនដែលឮប៉ូលីសនិយាយថា យកលុយទាំងនេះទៅប្រគល់ជូនរដ្ឋាភិបាលនោះទេ ។ ជួនកាល ខ្ញុំស្តាប់ឮថា ប៉ូលីសត្រូវការលុយទាំងនេះ ដើម្បីចំណាយលើប្រេងសាំង ជួនកាលយកទៅទិញស្រាផឹក ។ គ្រាមុន ពួកគេបានចុះមកមុនបុណ្យចូលឆ្នាំខ្មែរ ។ ជួនកាល ប៉ូលីសនិយាយថា នេះជាប្រាក់សំរាប់បង់ពន្ធ ប៉ុន្តែ ខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាប៉ូលីសចុះមកច្រើនដងម្ល៉េះ ហើយហេតុអ្វីបានជាត្រូវបង់ពន្ធ ។ ខ្ញុំគ្រាន់តែជាប្រជាពលរដ្ឋសាមញ្ញម្នាក់ប៉ុណ្ណោះ ។*

លោកស្រីពន្យល់ថា លោកស្រីបង់ប្រាក់អោយប៉ូលីស នៅពេលលោកស្រីមានប្រាក់ ពីព្រោះប៉ូលីសទាំងនេះមានឯកសណ្ឋានប៉ូលីស ហើយបើទោះបីជាលោកស្រីមិនដឹងពីឋានៈរបស់ប៉ូលីសទាំងនេះក្តី ក៏លោកស្រីគិតថា ប៉ូលីសទាំងនេះមានអំណាចធ្វើទោសទណ្ឌលោកស្រី និង គ្រួសារលោកស្រីដែរ ។ ម្តងនោះ នៅពេលលោកស្រីនិយាយថា លោកស្រីគ្មានប្រាក់ ប៉ូលីសទាំងនោះបានគំរាមដុតទូកគ្រួសារលោកស្រី និង បំផ្លាញសំណាញ់របស់គ្រួសារលោកស្រីចោល ប្រសិនបើលោកស្រីមិនបង់ប្រាក់អោយខ្លួន (ប៉ូលីស) ភ្លាមៗទេនោះ ។ លោកស្រី វ៉ាន បានពន្យល់បន្ថែមទៀតថា ៖

*ប្រសិនបើយើងមិននេសាទត្រីទេនោះ យើងមិនអាចរកកំរៃបានទេ ហើយយើងក៏គ្មានអ្វីញុំាដែរ ។ បញ្ហានេះពិតជាលំបាកណាស់ ហើយយើងមានកូនច្រើនទៀត ។ កូនទាំងអស់សុទ្ធតែនៅក្មេង ហើយកូនបងគេគ្មានការងារធ្វើទៀត ។ ជួនកាល ខ្ញុំគិតថា ខ្ញុំចង់សើចដូចក្មេង ម្នាក់នៅទីនោះ* ***(លោកស្រីចង្អុលទៅកុមារីម្នាក់ អាយុ ៣ឆ្នាំ)*** *ហើយមានប្រសាសន៍ថា លោកស្រីចង់មានអាយុដំណាលក្មេងនេះដែរដើម្បីគេចអោយផុតពីទុក្ខលំបាកនេះ ។*

លោកស្រី វ៉ាន មិនដែលទទួលបង្កាន់ដៃប្រាក់ដែលគាត់បានបង់ និង មិនហ៊ានសួរប៉ូលីសអំពីគោលបំណងយកប្រាក់នេះទេ ។ លោក វ៉ាន មិនបានគិតថា រូបលោកផ្ទាល់អាចធ្វើអ្វីចំពោះស្ថានភាពនេះទេ ដោយលោកគ្រាន់តែសង្ឃឹមថា ប៉ូលីសទាំងនេះនឹងមិនត្រឡប់មកម្តងទៀត ក្នុងពេលឆាប់ៗនោះ ។

**ចំពោះសំនួរដែលថា តើគ្រួសាររបស់លោកស្រីមានការភ័យខ្លាចឬអត់ លោកស្រីវ៉ានឆ្លើយតបយ៉ាងម៉ឺងម៉ាត់ថា ៖**

*ខ្ញុំមិនខ្លាចនោះទេ ! ប្រសិនបើខ្ញុំខ្លាច នោះខ្ញុំនឹងឈប់រកមុខរបរចិញ្ចឹមជីវិត ហើយប្រសិនបើខ្ញុំឈប់រកមុខរបរចិញ្ចឹមជីវិតនោះ ខ្ញុំមិនមានអាហារផ្គត់ផ្គង់កូនខ្ញុំទេ ដូច្នេះ ខ្ញុំមិនអាចខ្លាចបានទេ ។*

បទពិសោធន៍របស់លោកស្រី វ៉ាន ជាពិសេសកង្វះព័ត៌មានអំពីមូលហេតុដែលលោកស្រីត្រូវបង់ប្រាក់ និង កន្លែងទទួលប្រាក់នោះ ពិតជាបង្ហាញយ៉ាងច្បាស់នូវការប្រព្រឹត្តអំពើពុករលួយ ។ កង្វះទំនាក់ទំនងរវាងអ្នកបង់ និង អ្នកទទួលប្រាក់បង្កើតបានជាការចោទប្រកាន់ទៅលើអំពើពុករលួយ និង រួមចំណែកដល់ទម្លាប់ពុករលួយ ។ ទោះបីជាយ៉ាងនេះក្តី លោកស្រី វ៉ាន ជាញឹកញាប់បានបង់ប្រាក់ដល់ប៉ូលីសដោយខ្លាចបាត់បង់ទូកនេសាទរបស់លោកស្រីប៉ុណ្ណោះ ប៉ុន្តែលោកស្រីពុំបានដឹងថា ការបង់ប្រាក់នេះជំរុញទឹកចិត្តអោយប៉ូលីសទាំងនោះត្រឡប់មកលើកក្រោយទៀតនោះទេ ។ ជាលទ្ធផល ឥរិយាបថជាអវិជ្ជមានចំពោះការិយាធិបតេយ្យត្រូវបានលើកឡើងនៅពេលលោក និង លោកស្រី វ៉ាន ពណ៌នាអំពីស្ថានភាពដែលបង្ហាញពីទំនុកចិត្តតិចតួចរបស់គ្រួសារលោក និង លោកស្រី ទៅលើគុំរូដ៏រឹងមាំនៃអ្នកការិយាធិបតេយ្យទាំងអស់ ដែលមានអំណាច និង ពុករលួយ ។

## ៧.២ តើនេះជាការប្រឆាំងនឹងអំពើពុករលួយឬ ?

លោកស្រី វ៉ាន ជាស្ត្រីម្នាក់ដែលចូលចិត្តអ្នកដែលនិយាយថា ការប្រព្រឹត្តអំពើពុករលួយផ្ទុយទៅនឹងបទដ្ឋាន និង តម្លៃប្រពៃណីខ្មែរ ។ ស្ត្រីជាច្រើននៅក្នុងតំបន់នេះ ជាទូទៅ មានការយល់ដឹងអំពីការប្រព្រឹត្តខុសពីសីលធម៌នូវការប្រព្រឹត្តអំពើពុករលួយដែលខ្លួនកំពុងប្រឈម ហើយស្ត្រីទាំងនេះចូលរួមចំណែកជារៀងរាល់ថ្ងៃនៅក្នុងទំនៀមទំលាប់នៃអំពើពុករលួយ ។ ស្ត្រីទាំងនេះព្យាយាមការពារទ្រព្យសម្បត្តិ និង ប្រាក់កាសរបស់ខ្លួន ហើយមានក្តីរីករាយនៅពេលស្ត្រីទាំងនេះទទួលជោគជ័យក្នុងការឆបោកមន្ត្រី និង គេចមិនបង់ប្រាក់ ។ លោកស្រី វ៉ាន ពន្យល់ដោយញញឹមញាក់មាត់ថា ជួនកាលលោកស្រីមានប្រាក់ ប៉ុន្តែលោកស្រីគេចមិនបង់ប្រាក់ដល់ប៉ូលីសទេ ពីព្រោះលោកស្រីត្រូវការប្រាក់ទាំងនោះយកទៅទិញអង្ករសំរាប់គ្រួសារលោកស្រី ។

សីលធម៌របស់លោកស្រី វ៉ាន និង បទពិសោធន៍នៃការប្រព្រឹត្តយ៉ាងអយុត្តិធម៌មកលើលោកស្រីបានឆ្លុះបញ្ចាំងពីការយល់ឃើញផ្អែកសីលធម៌ជាមូលដ្ឋានរបស់លោកស្រី ដោយចង់អោយគេប្រព្រឹត្តអំពើយុត្តិធម៌ចំពោះរូបលោកស្រី និង ត្អូញត្អែរការយុត្តិធម៌ ។ ការណ៍នេះបង្ហាញយ៉ាងច្បាស់ណាស់ថា លោកស្រី វ៉ាន មិនមានទំនុកចិត្តទៅលើប៉ូលីស ហើយលោកស្រីគ្មានភាពជឿជាក់ទៅលើប្រព័ន្ធច្បាប់ស្មើភាពគ្នានោះទេ ។ បញ្ហានេះធ្វើអោយលោកស្រី វ៉ាន បកស្រាយស្រាយថា ការសុំប្រាក់នេះជាអំពើខុសច្បាស់ ។ លោកស្រីសន្និដ្ឋានថា ប្រាក់ដែលលោកស្រីបានបង់ត្រូវបានគេយកទៅចំណាយលើស្រា អាហារ ឬ បារី ហើយមិនបានដាក់ចូលរដ្ឋទេ ។ ទោះបីស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរយ៉ាងណាក្តី លោកស្រីនឹងធ្វើការប្រឈមមុខនៅពេលដែលប៉ូលីសដុតទូកនេសាទគ្រួសារលោកស្រីចោល ជួនកាលលោកស្រីបដិសេធមិនបង់ប្រាក់ ។ ផ្ទុយទៅវិញ លោកស្រីបានត្រឹមតែប្រមាថមាក់ងាយប៉ូលីសទាំងនោះដោយបញ្ជាក់អះអាងថា ការអនុវត្តនេះជាទង្វើដែលសង្គមមិនអាចទទួលយកបាន ។ ដូចលោក មីល័រ និង អាល់ (Miller et al.) បង្ហាញយ៉ាងត្រឹមត្រូវថា សេចក្តីត្រូវការសមភាព គឺមិនត្រូវបានប្រព្រឹត្តស្មើភាពចំពោះប្រជាពលរដ្ឋនោះទេ ក្រៅពីចំពោះមន្ត្រីរាជការ [១] ។

មីល័រ និង អាល់ (Miller et al.) អះអាងដោយយោងទៅតាមឯកសារនៅក្នុងរបាយការណ៍នេះថា ប្រជាពលរដ្ឋមានយុទ្ធសាស្ត្រអកម្ម និង សកម្មជាច្រើនក្នុងការដោះស្រាយជាមួយមន្ត្រីរាជការ [២] ។ ប៉ុន្តែ យោងតាម មីល័រ និង អាល់ (Miller et al.) ប្រតិកម្មមួយចំនួនរបស់ប្រជាពលរដ្ឋ ដូចយ៉ាងដូចជាលោកស្រី វ៉ាន មិនត្រូវបានទទួលស្គាល់ថា ជាការប្រឆាំងនោះទេ ក្នុងចំណោមប្រតិកម្មផ្សេងទៀត ។ លោក ជេម ស្កុត (James Scott) យល់ឃើញថា « ការប្រឆាំងរបស់កសិករដែលគ្រប់ដណ្តប់លើការប្រឆាំងរបស់ក្រុមដែលគ្មានអំណាចជាលក្ខណៈប្រចាំថ្ងៃ » ។ គោលគំនិតប្រឆាំងរបស់លោក ស្កុត (Scott) រួមមាន « ការបិទបាំងរឿងពិត ការក្លែងក្លាយ ការលួចឆក់ ភាពល្ងង់ខ្លៅ ការមួលបង្កាច់ ការបរិហារកេរ្តិ៍ ការដុតបំផ្លាញទ្រព្យសម្បត្តិ និង ការចងកម្ម» ហើយលោកបានថ្លែងបន្ថែមទៀតថា «សកម្មភាពទាំងនេះទាមទារការសំរបសំរួល ឬ ការរៀបចំផែនការតិចតួច » ។ ជាញឹកញាប់ សកម្មភាពទាំងនេះតំណាងអោយប្រភេទមួយនៃការជួយខ្លួនឯង ហើយជាធម្មតា សកម្មភាពទាំងនេះជៀសផុតពីការប្រឈម ជានិមិត្តរូបដោយផ្ទាល់ជាមួយអាជ្ញាធរ « បទដ្ឋាននៃក្រុមឥស្សរជន » [៣] ។ គោលគំនិតលោក ស្កុត (Scott) អំពី «ប្រភេទនៃការប្រឆាំងដោយផ្អែកលើមូលដ្ឋានប្រចាំថ្ងៃ » មានលក្ខណៈសមស្រម ជាពិសេសសំរាប់ការពន្យល់បកស្រាយអំពីមធ្យោបាយប្រឆាំងនឹងកាប្រព្រឹត្តអំពើពុករលួយរបស់ប្រជាពលរដ្ឋក្រីក្រ ។ ដូច្នេះ ស្ថានភាពដែលកើតឡើងចំពោះលោកស្រី វ៉ាន អាចត្រូវបានវិភាគថា ជាប្រភេទនៃការប្រឆាំងអកម្មប្រចាំថ្ងៃ ។

ទោះបីយ៉ាងនេះក្តី អ្វីដែលលោក ស្កុត (Scott) កំណត់ថា ជា «ប្រភេទនៃការប្រឆាំងដោយផ្អែកលើមូលដ្ឋានប្រចាំថ្ងៃ» ចំពោះលោកស្រី វ៉ាន គឺជាយុទ្ធសាស្ត្រដើម្បីរស់ជាសំខាន់ ។ លោកស្រីដឹងច្បាស់អំពីយុទ្ធសាស្ត្ររបស់ខ្លួន ហើយលោកស្រីមានអារម្មណ៍ថា ការប្រឆាំងដោយសកម្ម និង បើកចំហ មិនអាចធ្វើទៅបានដោយគ្មានគ្រោះថ្នាក់ និង ផលវិបាកធ្ងន់ធ្ងរនោះឡើយ ។ បើទោះបីប្រជាពលរដ្ឋយល់ថា ការបង់ប្រាក់ផ្ទុយនឹងសីលធម៌ និង ច្បាប់ក៏ដោយ ក៏លោកស្រី វ៉ាន និង ប្រជាពលរដ្ឋក្រីក្រដទៃទៀត សំដែងនូវការព្រួយបារម្ភរមថា ការប្រឆាំងសកម្មមិនទំនងជាអាចធ្វើទៅបានទេ ពីព្រោះប្រជាពលរដ្ឋទាំងនេះមិនមានទំនុកចិត្តទៅលើច្បាប់ ដូច្នេះ ប្រជាពលរដ្ឋទាំងនេះមានអារម្មណ៍ថា គ្មានសុវត្ថិភាពក្នុងការប្តឹងតវ៉ា ។

## ៧.៣ មានការលើកទឹកចិត្តតិចតួចដើម្បីបង្កើនផលិតភាព

មធ្យោបាយមួយដែលគេតែងតែលើកឡើងក្នុងការរំដោះខ្លួនចេញពីភាពក្រីក្រនោះ គឺតាមរយៈការកើនឡើងនូវកំណើនសេដ្ឋកិច្ច និង ផលិតភាពខ្ពស់ ។ បុគ្គលវណ្ណៈកណ្តាល និង អ្នកដែលមានជីវភាពធូរធារ ជាញឹកញាប់និយាយថា ប្រជាពលរដ្ឋក្រីក្រមានការខ្ជិលច្រអូស ដែលនាំអោយខ្លួនធ្លាក់ក្នុងភាពក្រីក្រ ដែលផ្ទុយទៅនឹងអ្នកមានដែលមានទ្រព្យសម្បត្តិ តាមរយៈការខិតខំធ្វើការដូចបានលើកឡើងនៅក្នុងសេចក្តីថ្លែងមួយថា « *ខំធ្វើការទើបមាន* » ។ ប៉ុន្តែកសិករក្រីក្រ ជាញឹកញាប់សំរេចមិនធ្វើការបង្កើនផលិតភាពរបស់ខ្លួនដោយសារហេតុផលជាច្រើន ។



**ក្មេងកំពុងមើលគេជួសជុលម៉ូតូ**

ករណីខាងក្រោមនេះ (ប្រអប់ ៧) រៀបរាប់ពីកង្វះគ្រឿងលើកទឹកចិត្តរបស់លោក សុខា ក្នុងការបង្កើនផលិតភាពរបស់លោកដោយសារលទ្ធផលដោយផ្ទាល់នៃកង្វះទំនាក់ទំនង និង ទំនុកចិត្តតិចតួចទៅលើអ្នកជិតខាង និង រដ្ឋាភិបាល និង អំពើពុករលួយក្នុងចំណោមប៉ូលីស ។ ករណីនេះបង្ហាញថា យុទ្ធសាស្ត្រប្រើកំលាំងតិច និង ទិន្នផលទាប គឺជាយុទ្ធសាស្ត្រចំណាយដ៏មានប្រសិទ្ធភាពបំផុត នៅពេលចង់បានកំណើនផលិតភាព ។

**ប្រអប់ទី ៧ : បទសម្ភាសន៍ជាមួយលោក សុខា**

លោក សុខា គឺជាកសិករដែលមានវ័យ ៦៩ឆ្នាំ ។ លោក សុខា រស់នៅក្នុងផ្ទះធំមួយជាមួយភរិយាដែលមានអាយុប្អូនលោក ១២ឆ្នាំ កូនស្រីរបស់លោក ប្តីរបស់នាង និង កូនរបស់អ្នកទាំងពីរនៅក្នុងតំបន់ជនបទ ។ គ្រួសារនេះមានសួនច្បារដ៏ស្រស់ស្អាតមួយ ដែលមានផ្កាចំរុះពណ៌គួបផ្សំនឹងឈើហូបផ្លែ ។ លោក សុខា គឺជាអតីតគ្រូបង្រៀន ប៉ុន្តែបន្ទាប់ពីមានការផ្លាស់ប្តូរថ្នាក់គ្រប់គ្រងមកបច្ចុប្បន្ននេះ លោក សុខា ធ្វើការនៅលើដីកសិដ្ឋានរបស់លោកក្បែរទន្លេ ។ លោក សុខា បង្ហាញ

នូវការយល់ដឹងយ៉ាងច្រើនអំពីស្ថានភាពខាងនយោបាយ និង សង្គមនៅក្នុងប្រទេសកម្ពុជា ហើយគេដឹងថា ជាញឹកញាប់ លោក សុខា ស្តាប់វិទ្យុ អានកាសែត នៅពេលនរណាម្នាក់ទិញ និង យកមកពីទីរួមខេត្ត ហើយលោកចូលរួមក្នុងវេទិកាសាធារណៈ ដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ប្រសិនបើអង្គការបង់ថ្លៃធ្វើដំណើរជូនលោក ។ លោក សុខា មានសេចក្តីរីករាយក្នុងការពិភាក្សាអំពីបញ្ហាដែលងាយរសើបជាលក្ខណៈឯកជន ប៉ុន្តែ មិនអនុញ្ញាតអោយគេថតសំលេងបទសម្ភាសន៍របស់លោកទេ ដោយខ្លាចកើតមានផលពិបាកមួយចំនួនមកលើរូបលោក និង គ្រួសាររបស់លោក ។

លោក សុខា ពន្យល់ថា លោកមានការព្រួយបារម្ភដោយសារគ្មានការផ្តល់គ្រឿងលើកទឹកចិត្តដល់រូបលោកក្នុងការបង្កើនផលិតផលផ្លែឈើ ស្រូវ និង បន្លែរបស់លោក ហើយលោក សុខា មានប្រសាសន៍ថា ការិតជីវភាពរស់នៅក្នុងតំបន់នេះពិបាកនឹងយល់ណាស់ :

*តំបន់នេះអនុគ្រោះដល់កសិកម្មយ៉ាងខ្លាំង ពីព្រោះយើងរស់នៅក្បែរទន្លេ ប៉ុន្តែយើងមិនអាចធ្វើការដាំដុំនៅលើដីបាន ពីព្រោះយើងគ្មានទីផ្សារសំរាប់លក់ផលិតផលរបស់យើង [...] ។ យើងអាចដាំ សណ្តែក ស្រូវ ពោត ថ្នាំជក់ ប៉េងប៉ោះ ។ល។ ប៉ុន្តែយើងគ្មានហេតុផលក្នុងការវិនិយោគលើផលិត ផលទាំងនេះទេ ពីព្រោះយើងគ្មានកន្លែងលក់ផលិតផលទាំងនេះ ។ យើងអាចនាំផលិតផលទៅកាន់ ទីផ្សារ* ***(នៅទីរួមខេត្ត)*** *ប៉ុន្តែ ថ្លៃដឹកជញ្ជូនផលិតផលទៅទីផ្សារមានការិតខ្ពស់ណាស់ ហើយយើងនឹងបាត់បង់ប្រាក់ចំណេញជាមិនខាន [...] ខ្ញុំអាចដាំប៉េងប៉ោះបានច្រើន ហើយខ្ញុំចង់នាំចេញផលិតផលនេះ និង ប្រើប្រាស់ផលិតផលនេះសំរាប់គោលបំណងផ្សេងទៀត ។ ដូចប្រជាជនវៀតណាម ពួកគេធ្វើជាប៉េងប៉ោះកំប៉ុង ប៉ុន្តែយើងគ្មានចំណេះដឹងផ្នែកបច្ចេកទេសក្នុងការធ្វើដូច្នោះនោះទេ [...] ។ យើងមិនរំពឹងអោយរដ្ឋាភិបាលធ្វើកិច្ចការច្រើននោះទេ ប៉ុន្តែគ្រាន់តែសុំអោយជួយរកទីផ្សារសំរាប់លក់ផលិតផលរបស់យើងប៉ុណ្ណោះ ។*

លោក សុខា និង កូនប្រសារប្រុសរបស់គាត់ មានបាវស្រូវទម្ងន់ ១០០គក្រ. ជាច្រើនបាវស្តុកនៅក្នុងផ្ទះ ។ គ្រួសាររបស់លោកនឹងប្រើប្រាស់អង្ករទាំងនេះសំរាប់ខ្លួនឯង ឬ លក់អោយឈ្មួញកណ្តាលនៅពេលមានហាងឆេង ។ ជាធម្មតា ឈ្មួញកណ្តាលចុះមកទិញដល់ផ្ទះ ហើយទិញ លក់ស្រូវ ដោយទទួលបានកំរៃយ៉ាងច្រើន ប៉ុន្តែសព្វថ្ងៃនេះ ស្រូវមានតម្លៃថោកពេក ដូច្នេះឈ្មួញទាំងនេះបានស្តុកស្រូវទុក ។ លោក សុខា ដឹងពីរបៀបធ្វើវិនិយោគ និង មានស្មើរគ្រប់ផលិតផល ប៉ុន្តែលោក សុខា មានអារម្មណ៍ថា សង្គមកំពុងតែជួបនូវវិបត្តិដ៏ធំនាពេលបច្ចុប្បន្ននេះ ដែលរារាំងដល់ដំណើរការវិនិយោគ និង ការអភិវឌ្ឍ ។ លោក សុខា រៀបរាប់ថា :

*ខ្ញុំមានដី ១០ ហិកតា ប៉ុន្តែធ្វើការដាំដុំបានតែ ១ ហិកតាប៉ុណ្ណោះ ។ ដីមួយចំនួនគ្របដណ្តប់ទៅដោយព្រៃ ។ ខ្ញុំចង់ខ្ចីឥណទានធនាគារដើម្បីធ្វើការដាំដុំនៅលើដីទាំងអស់ ប៉ុន្តែសព្វថ្ងៃនេះ ស្ថានភាពនយោបាយ គឺមិនអំណោយផលសោះ ដូច្នេះខ្ញុំសំរេចចិត្តរង់ចាំ ។ ខ្ញុំមានព្រៃឫស្សីមួយ ហើយខ្ញុំចង់នាំចេញឫស្សី ក៏ប៉ុន្តែបច្ចុប្បន្ននេះ ការនាំចេញមានការលំបាកណាស់ ។ ប្រសិនបើចង់លក់ដើមឫស្សី នៅពេលឥឡូវនេះ ខ្ញុំត្រូវបង់ពន្ធនៅប៉ុស្តិ៍ត្រួតពិនិត្យជាច្រើន ហើយខ្ញុំនឹងគ្មានសល់ប្រាក់ចំណេញនោះទេ ។ កាលពីមុន ខ្ញុំបានព្យាយាមដែរ ប៉ុន្តែពុំផ្តល់លទ្ធផលល្អទេ [...] ។ អ្នករត់ការនឹងមិនទិញឫស្សីទេនាពេលបច្ចុប្បន្ននេះ ដោយសារតែស្ថានភាពនយោបាយដ៏តានតឹង ។ ប្រសិនបើយកដើមឫស្សីទៅដាក់លើទន្លេ* ***(សំរាប់ដឹកជញ្ជូន)*** *ដោយខ្លួនឯង មន្ត្រីនគរបាលនឹងចុះមកទារប្រាក់ជាពុំខាន ។ ខ្ញុំមិនដឹងថា មកពីមូលហេតុអ្វីនោះទេ ការនាំចេញឫស្សីពុំមែនជារឿងខុសច្បាប់ទេ ពីព្រោះឫស្សីជាកម្មសិទ្ធិរបស់ខ្ញុំ និង សំរាប់ប្រើប្រាស់ក្នុងស្រុកដោយប្រជាជនកម្ពុជា ។ ខ្ញុំគ្រាន់តែដឹងថាពួកគេត្រូវការប្រាក់ [...] ។ ខ្ញុំពិបាកនឹងនិយាយអំពីទស្សនៈផ្ទាល់ចំពោះទង្វើនេះណាស់ នេះជារឿងធម្មតានៅក្នុងប្រទេសកម្ពុជា ហើយទង្វើបែបនេះត្រូវបានហៅថា អំពើពុករលួយ ។ ខ្ញុំគ្មានអំណាចធ្វើការប្រឆាំងនឹងអំពើនេះទេ ។*

លោក សុខា តូញត្អែរយ៉ាងខ្លាំងអំពីស្ថានភាពនយោបាយទាំងនៅថ្នាក់ជាតិ និង ថ្នាក់ឃុំ ហើយលោក សុខា មានអារម្មណ៍ថា កំរិតនៃអំពើពុករលួយកាន់តែធ្ងន់ធ្ងរទៅៗ បើប្រៀបធៀបនឹង ទសវត្សរ៍ឆ្នាំ១៩៦០ ។ លោក សុខា មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីកង្វះសាមគ្គីភាពនៅក្នុងសង្គមដែលរៀបរាប់ដោយលោកផ្ទាល់ ។

*សព្វថ្ងៃនេះ គ្មានសាមគ្គីភាពនោះទេ ក្រៅពីការលួច ជម្លោះ ការឈ្លោះប្រកែក និង ការកាប់សម្លាប់នៅក្រិតសហគមន៍ និង ជាតិ [...] ។ បញ្ហានេះមិនត្រឹមតែជះឥទ្ធិពលមកលើគ្រួសារខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជះឥទ្ធិពលទៅលើសង្គមទាំងមូលទៀតផង [...] ។ បើគ្មានសាមគ្គីភាពទេ យើងមិនអាចអភិវឌ្ឍសង្គមបានទេ ។ ស្មារតីទទួលខុសត្រូវនៃភាពជាអ្នកដឹកនាំ និង សីលធម៌សង្គម និង វប្បធម៌បានធ្លាក់ចុះចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០មក ។ មនុស្សបាត់បង់ភាពជឿជាក់លើគ្នាទៅវិញទៅមក ។ សង្គមខ្មែរទទួលរងឥទ្ធិពលនៃគំនិតដ៏យង់ឃ្នងនាយុគសម័យ ប៉ុល ពត ខណៈដែលរចនាសម្ព័ន្ធសង្គមត្រូវបានបំផ្លាញ ។ សព្វថ្ងៃនេះ យើងនៅមានគំនិតដែលនៅសេសសល់ពីយុគសម័យ ប៉ុល ពត នៅឡើយ ។*

លោក សុខា បង្ហាញយ៉ាងច្បាស់ថា លោកពិតជាមនុស្សដែលពោរពេញដោយចំណេះដឹង និង គំនិតផ្តួចផ្តើមក្នុងការធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់លោក តាមរយៈការបង្កើនផលិតភាពដីកសិកម្មរបស់លោក ក៏ប៉ុន្តែលោកយល់ឃើញថា អំណាចទំនាក់ទំនងក្នុងមូលដ្ឋានរារាំងដល់ចំណេះដឹង និង គំនិតផ្តើមរបស់លោក ។ លោក សុខា បានជួបប្រទះនូវការប្រព្រឹត្តអំពើពុករលួយនៅពេលដែលលោកព្យាយាមលក់ផលិតផលដែលលើសពីតំរូវការគ្រួសារ ហើយលោកបានកំណត់ថា ដោយខ្វះបណ្តាញដ៏មានឥទ្ធិពល និង ទំនុកចិត្តនៅក្នុងបរិស្ថានសហគមន៍យុទ្ធសាស្ត្រល្អប្រសើរបំផុត គឺគ្រាន់តែដាំដុះលើដីល្មមគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះបានហើយ ។

លោក សុខា បានបញ្ចេញទស្សនៈបន្ថែមទៀតថា ពុំមានទំនុកចិត្តជាក់លាក់ និង ទូទៅទៅលើបរិស្ថានសហគមន៍ក្នុងការប្រឆាំងរួមគ្នាទៅនឹងការប្រព្រឹត្តអំពើពុករលួយ ឬ ការសហការក្នុងការដាំដុះនោះទេ ។ ជាលទ្ធផលលោក សុខា ប្រើចំណេះដឹងរបស់ខ្លួនដើម្បីបង្កើនជាអតិបរមានូវកំរិតជីវភាពរស់នៅរបស់គ្រួសារលោកដោយគ្រាន់តែដាំដំណាំសំរាប់ផ្គត់ផ្គង់គ្រួសារប៉ុណ្ណោះ ពីព្រោះលោកខ្វះដើមទុនសំរាប់ការវិនិយោគបន្ថែម[៤] ។

## ៧.៤ រចនាសម្ព័ន្ធរដ្ឋអំណាចដែលធ្វើអោយការប្រឆាំងអំពើពុករលួយស្ថិតនៅក្នុងភាពគ្រោះថ្នាក់

ស្ថានភាពដូចករណីចំនួនពីរដែលបានរៀបរាប់ខាងលើ គឺជាបាតុភូតថ្នាក់ជាតិមួយដែលប្រជាពលរដ្ឋក្រីក្រងាយនឹងធ្លាក់ខ្លួនជាជនរងគ្រោះដោយសារការកេងប្រវ័ញ្ច ។ ដូច្នេះយុទ្ធសាស្ត្រដែលល្អប្រសើរ

បំផុតនោះ គឺត្រូវទប់ស្កាត់នូវគំនិតផ្តួចផ្តើមនានា ។ ស្ថានភាពបែបនេះកាន់តែមានសភាពធ្ងន់ធ្ងរបន្ថែមទៀត ដោយ សាររចនាសម្ព័ន្ធគាំទ្រដ៏រឹងមាំដែលបង្កើតនូវឋានៈអំណាចផ្សេងៗគ្នា ត្រូវបានប្រើដោយបំពានដោយក្រុមមួយចំនួន ។ របាយការណ៍ និង ការស្ទង់មតិជាច្រើនដែលបានពីការសិក្សានេះបង្ហាញថា ប៉ូលីសទាញយកផលប្រយោជន៍ពីឋានៈដ៏មានអំណាចរបស់ខ្លួន ហើយចំណែកឯ អាជ្ញាធរមូលដ្ឋានដែលនៅក្នុងផ្នែកដទៃផ្សេងទៀត ក៏ប្រព្រឹត្តដូច្នោះដែរ ដូចមានបង្ហាញនៅជំពូកមុនៗ ។

អ្នកទទួលប្រាក់សំណូកទាញយកផលប្រយោជន៍ពីប្រជាពលរដ្ឋដែលគ្មានបណ្តាញដ៏មានឥទ្ធិពល គ្មានការយល់ដឹងផ្នែកច្បាប់ និង គ្មានអំណាច តាមរយៈការគាបសង្កត់ជិះជាន់ប្រជាពលរដ្ឋ ព្រមទាំងយកប្រាក់ដោយមិនផ្តល់នូវហេតុផល ។ បញ្ហានេះមានការពិបាកណាស់សំរាប់ប្រជាពលរដ្ឋសាមញ្ញ ដូចជាគ្រួសាររបស់លោកស្រី វ៉ាន និង លោក សុខា ក្នុងការតវ៉ាប្រឆាំងនឹងទង្វើបែបនេះ ពីព្រោះលោក និង លោកស្រី វ៉ាន ខ្លាចមានផលវិបាកនានា ព្រមទាំងគ្មានអន្តរាគមន៍ និង ការពារពីខ្សែរយៈ ។ គ្រួសារលោក វ៉ាន និង សុខា និង អ្នកដទៃផ្សេងទៀតបានលើកឡើងថា ជាធម្មតា អ្នកជិតខាងមិនជួយគ្នាទេ ពីព្រោះអ្នកជិតខាងទាំងនេះមានជីវភាពទីទ័លក្រជាមួយនឹងកំហិតនូវលទ្ធភាពក្នុងការបង្កើតបណ្តាញខ្សែបណ្តោយ និង បង្កើតនូវទំនុកចិត្តជាក់លាក់ដើម្បីប្រឆាំងទៅនឹងការគាបសង្កត់តាមមូលដ្ឋាននៅក្នុងសហគមន៍នានា ។ ប៉ុន្តែលោក វ៉ាន ពិតជាមានទំនុកចិត្ត ក្នុងការនេសាទត្រីជាមួយអ្នកជិតខាងរបស់លោក ដែលការណ៍នេះបង្ហាញថា មានវត្តមាននៃទំនុកចិត្តជាក់លាក់មួយចំនួនដែរក្នុងចំណោមអ្នកជិតខាង ។

ដូចគ្រួសារលោក វ៉ាន ដែរ គ្រួសារជាច្រើនរស់នៅលើដីដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ។ គ្រួសារលោក វ៉ាន ត្រូវបានបុគ្គល «មានអំណាច» បណ្តេញចេញពីដីចាស់របស់ខ្លួន ដោយទាមទារយកដីនោះភ្លាមៗ ហើយគ្មាននរណាហ៊ានជំទាស់ប្រឆាំងនោះឡើយ ។ បទពិសោធន៍ស្រដៀងគ្នាមួយបានកើតឡើងទៅលើស្ត្រីម្នាក់ផ្សេងទៀត ក្នុងពេលថ្មីៗកន្លងទៅនេះ ។ ស្ត្រីរូបនោះធ្វើការពន្យល់រៀបរាប់ថា បានលក់ដីរបស់ខ្លួនដោយខ្លាចក្រែងដីនេះធ្លាក់ទៅលើក្រុមមនុស្ស « ដែលមានអំណាច » :

*យើងមានការព្រួយបារម្ភថា ប្រសិនបើយើងមិនលក់ដីទេនោះ ពួកគេ (អភិបាលស្រុក) នឹងទាមទារយកដីនេះទទេដោយពុំបង់ប្រាក់សំរាប់ការយកដីនេះឡើយ ។ ប្រជាពលរដ្ឋនៅទីនេះមានការភ័យខ្លាចពីព្រោះខ្លួនគ្មានអំណាច ។ ពួកគេ (អភិបាលស្រុក) គ្រាន់តែនិយាយថា ប្រសិនបើយើងមិនលក់ដីទេ ពួកគេនឹងរឹបអូសយកដីនេះ ។ ប៉ុន្តែបើយើងយល់ព្រមលក់ យើងនឹងទទួលបានប្រាក់តិចតួចសំរាប់តែទិញអាហារ*

*ញាំតែប៉ុណ្ណោះ ។ លើសពីនេះទៅទៀត យើងមិនអាចរស់នៅទីនេះបានទេ នៅពេលពួកគេត្រូវការដីនេះ ។ យើងមានប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លី ប៉ុន្តែយើងគិតថា គួរទទួលយកប្រាក់ទាំងនេះ ។*
(ស្ត្រីក្នុងវ័យខ្ទង់ ២៥ឆ្នាំ រស់នៅតំបនជនបទ់ដែលមិនសូវឆ្ងាយ) (៥) ។

ដូចបានលើកឡើងសំរង់សំដីខាងលើ ស្ត្រីរូបនេះខ្លាចបាត់បង់អ្វីៗដែលខ្លួនមាន ប្រសិនបើខ្លួនមិនគោរពតាមការណែនាំទេនោះ ។ ប្រជាពលរដ្ឋក្រីក្រដូចជាស្ត្រីរូបនេះ មិនអាចធ្វើការប្រឆាំងសកម្មបានទេ ពីព្រោះប្រជាពលរដ្ឋទាំងនេះគ្មានបណ្តាញដែលមានឥទ្ធិពល ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋទាំងនេះប្រើនូវប្រភេទនៃការប្រឆាំងប្រចាំថ្ងៃរបស់ខ្លួនដូចជាការចរចាដែលមានលក្ខណៈដូចគ្នាទៅនឹងការចរចាបញ្ចុះថ្លៃនៅលើទីផ្សារដូច្នោះដែរ ។ វិធីផ្សេងដទៃទៀតនៃការប្រឆាំងដូចជា ការនិយាយកុហកប៉ូលីសថា មិន មានប្រាក់ (ដូចករណីខ្លះចំពោះលោកស្រី វ៉ាន ជាដើម) ចូលរួមពិភាក្សា ប្រសិនបើអាចធ្វើទៅបាន និង មិនប្រថុយគ្រោះថ្នាក់ខ្លាំង ឬ ដើរចេញអោយឆ្ងាយ / បើកគេច (ជាញឹកញាប់ ប្រើសំរាប់ចរាចរ) ដោយគ្មានប្រតិកម្មតប ទៅនឹងការទាមទាររបស់ប៉ូលីស ។

(ការយល់ឃើញ) អំពីការទាមទារប្រាក់ជាប្រចាំនៅពេលដែលប្រជាពលរដ្ឋធ្វើទំនាក់ទំនងជាមួយមន្ត្រីរាជការនៅតាមការិយាធិបតេយ្យ និង ស្ថាប័នមូលដ្ឋានធ្វើអោយគ្រួសារលោក វ៉ាន មិនបានធ្វើសំបុត្រកំណើត ឬ ចុះបញ្ជីអត្រានុកូលដ្ឋានអោយកូនរបស់ខ្លួន ព្រមទាំងធ្វើអោយថយចុះនូវផលិតភាពរបស់លោកសុខា ។ ប៉ុន្តែយុទ្ធសាស្ត្របែបនេះមិនត្រឹមតែមិនមាននិរន្តរភាពយូរអង្វែងប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបង្កើតនូវឧបសគ្គច្រើនថែមទៀត ចំពោះការប្រឆាំងតទល់ និង ការអភិវឌ្ឍ ។

ផលវិបាកនានានៃទំនាក់ទំនងអំណាចដែលមិនស្មើគ្នារវាងប្រជាពលរដ្ឋ និង មន្ត្រីរាជការ ភាគច្រើនត្រូវបានដោះស្រាយដោយព្យាយាមធ្វើជារាក់ទាក់នឹងមន្ត្រីនោះ ចរចាដោយសន្តិវិធីក្នុងការរកដំណោះស្រាយដែលអាចលៃលកបានដោយការផ្តើមបង់ប្រាក់ ការអង្វរករ បើទោះបីជាមន្ត្រីទាំងនោះ អាចនឹងប្រព្រឹត្តមិនសមស្របចំពោះខ្លួនក៏ដោយ ហើយទីបំផុតទទួលយកការប្រព្រឹត្តដែលមិនជាទីពេញចិត្តដើម្បីជៀសវាងគ្រោះថ្នាក់លើកក្រោយ ។ ដូច្នេះកង្វះការប្រឆាំងសកម្ម គួរត្រូវបានចាត់ទុកថា ជាការទទួលយកនូវការប្រព្រឹត្តបែបនេះ (អំពើពុករលួយ) ប៉ុន្តែ នេះជាការបង្ហាញនូវទំនុកចិត្តតិចតួចនៅក្នុងសង្គមក្នុងការធានានូវការប្រព្រឹត្តដោយយុត្តិធម៌ ការជួយជ្រោមជ្រែង និង ជំហរទន់ខ្សោយ ។

---

១ Miller et al. ឆ្នាំ ២០០១ : ៧៩ ។ យោងតាម Miller et al. ភាពខុសគ្នារវាងប្រភេទនៃការប្រឆាំងអកម្ម និង សកម្មនេះមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេសនៅក្នុងប្រទេសប្រកាន់របបផ្តាច់ការ និង ក្រោយរបបផ្តាច់ការ ។

២ Miller et al. ឆ្នាំ២០០១ : ៩៣ - ១៣២ ។

៣ Scott ឆ្នាំ ១៩៨៥ : ២៩ ។

៤ ត្រូវបានគេលើកទឹកចិត្តអោយធ្វើការសិក្សាដ៏ទូលំទូលាយបន្ថែមទៀតស្តីពីឧបសគ្គនានា ចំពោះការវិនិយោគរបស់កសិករក្រីក្រទៅលើការផលិតដំណាំពាណិជ្ជកម្ម (សំរាប់លក់) ។

៥ Nissen ឆ្នាំ២០០៤ ។